ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៧១៩៣ ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងចុះបញ្ជី សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សម្រាប់នីតិបុគ្គល

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.–**

ប្រកាសនេះ មានគោលបំណងធានាការពារសិទ្ធិសេរីភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬនីតិបុគ្គលផ្សេងទៀត ក្នុងការចូលរួមប្រមូលផ្តុំ ឬចងសម្ព័ន្ធគ្នា ដើម្បីបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលថ្មីមួយ ស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**ប្រការ ២. –**

ប្រកាសនេះមានគោលដៅកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល។

**ប្រការ ៣. –**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះនីតិបុគ្គលដែលរួមគ្នាបង្កើតជាសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដើម្បីធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ការបង្កើត និងការចុះបញ្ជីសមាគម
## និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សម្រាប់នីតិបុគ្គល

**ប្រការ ៤. –**

ការបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល ត្រូវមានសមាជិកស្ថាបនិកដែលជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ឬនីតិបុគ្គលដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ពាក់ព័ន្ធជាធរមាន យ៉ាងហោចចំនួន ០៣(បី)ឡើងទៅ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល ត្រូវមានប្រធាន ០១(មួយ)រូប ឬតំណាងស្ថាបនិក ០១(មួយ)រូប សម្រាប់រៀបចំសំណុំបែបបទដើម្បីស្នើសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ។

**ប្រការ ៥. –**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល ត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃដោយបំពេញសំណុំលិខិតដូចខាងក្រោម៖

១. ពាក្យសុំចុះបញ្ជីចំនួន ០២(ពីរ)ច្បាប់

២. ប្រកាស ឬឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលជាសមាជិក ឬនីតិបុគ្គលផ្សេងទៀត ចំនួន ០១(មួយ)ច្បាប់

៣. លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គលដែលត្រូវបង្កើត ពីមេឃុំ ឬចៅសង្កាត់ ចំនួន ០១(មួយ)ច្បាប់

៤. ជីវប្រវត្តិរបស់ប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬនីតិបុគ្គលដែលជាស្ថាបនិកម្នាក់ៗមានបិទរូបថតបច្ចុប្បន្ន ទំហំ ៤គុណនឹង៦ ចំនួន ០២(ពីរ)ច្បាប់

៥. លក្ខន្តិកៈចុះហត្ថលេខាដោយប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គលដែលត្រូវបង្កើត ចំនួន ០២(ពីរ)ច្បាប់។

**ប្រការ ៦. –**

លក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល ត្រូវមានខ្លឹមសារស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់នានាជាធរមាន ហើយត្រូវចែងនូវចំណុចសំខាន់ៗដូចបានកំណត់ក្នុងមាត្រា ៧ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**ប្រការ ៧. –**

បែបបទ និងនីតិវិធីនៃការចុះបញ្ជីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលបានចែងក្នុងមាត្រា ៨ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**ប្រការ ៨. _**

កម្រៃសេវាសម្រាប់ការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៣
## ការធ្វើសកម្មភាពរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សម្រាប់នីតិបុគ្គល

**ប្រការ ៩. _**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល នឹងក្លាយជានីតិបុគ្គលចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃបានចុះបញ្ជី។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គលដែលមិនបានចុះបញ្ជី មិនត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

**ប្រការ ១០. _**

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល ត្រូវប្រកាន់ជំហរអព្យាក្រឹតចំពោះគ្រប់គណបក្សនយោបាយនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១១. _**

បទប្បញ្ញត្តិមាត្រា ១០ នៃជំពូកទី២ មាត្រា ១៨ នៃជំពូកទី៤ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៥ នៃជំពូកទី៥ មាត្រា ២៦ មាត្រា ២៨ និងមាត្រា ២៩ នៃជំពូកទី៦ និងមាត្រា ៣០ មាត្រា ៣១ មាត្រា ៣២ និងមាត្រា ៣៦ នៃជំពូកទី៧ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវយកមកអនុវត្តផងដែរចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គល ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ ១២. _**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៣. _**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សារាជធានី ខេត្ត និងគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...សុក្រ ១២រោច.....ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...០៧...ខែ...ឧសភា...ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

***កន្លែងទទួល៖***
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ